ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខៈ០៣១/២២ អអរ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តកំពង់ធំ"

ព្រឹកថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តកំពង់ធំ»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ឈុន ឈន់ ប្រធានក្រុមប្រឹក្សាខេត្តកំពង់ធំ**
- **លោក គៀង សេងគី មេឃុំត្បូងក្រពើ ស្រុកសន្ទុក**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបង្ហាញសាធារណជនឱ្យបានយល់ច្បាស់ពីយន្តការប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជាប្រវត្តិសាស្ត្រកម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលរដ្ឋបាលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឃុំ-សង្កាត់។

## I. សេចក្តីផ្តើម

ខេត្តកំពង់ធំ មានព្រំប្រទល់ជាប់ខេត្តព្រះវិហារ ស្ទឹងត្រែង ក្រចេះ កំពង់ចាម កំពង់ឆ្នាំង ពោធិ៍សាត់ និងសៀមរាប ចែកជាក្រុង០១ ស្រុក០៨ ឃុំ៧៣ សង្កាត់០៨ ភូមិ៧៦៧ ដែលមានប្រជាពលរដ្ឋចំនួន ១៧៧.៧២៨គ្រួសារ ស្មើនឹង ៨២០.៩៦០នាក់ ស្រី៤១៧.០៣៨នាក់ ដែលវិស័យកសិកម្មជាវិស័យចំបងក្នុងការរក្សាលំនឹងសេដ្ឋកិច្ចជូនប្រជាពលរដ្ឋ ។

## II. វឌ្ឍនភាពការងារ

- **ក្រុមប្រឹក្សាខេត្ត**

- ផ្អែកតាមគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវច្បាប់រៀបចំអង្គការ ដែលជាមូលដ្ឋានគតិយុត្តិសម្រាប់កិច្ចការកំណែទម្រង់

រដ្ឋបាលតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងបានបង្កើតឱ្យមានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមរយៈការបោះឆ្នោតអសកល។

- ខេត្តមានសមាជិកក្រុមប្រឹក្សាខេត្តចំនួន ២៥នាក់ សមាជិកក្រុមប្រឹក្សាក្រុងស្រុក ចំនួន ១៦៩នាក់ និងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ចំនួន ៥៧៧នាក់។ ក្នុងឆ្នាំ ២០២១ ក្រុមប្រឹក្សាខេត្តបានបើកកិច្ចប្រជុំរបស់ខ្លួនបានចំនួន ៦៦លើក ក្នុងនោះប្រជុំសាមញ្ញ ១២លើក វិសាមញ្ញ ០៤លើក គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ១២លើក និងគណៈកម្មាធិការលទ្ធកម្ម ៣៨លើក។ ដោយសារតែវិបត្តិនៃជំងឺកូវីដ១៩ ក្រុមប្រឹក្សាបានអាក់ខានមិនបានរៀបចំវេទិកាសាធារណៈពិគ្រោះយោបល់របស់ខ្លួនដើម្បីប្រមូលសំណើ សំណូមពរ និងកង្វល់របស់ប្រជាពលរដ្ឋនៅមូលដ្ឋានឡើង។

❖ **ឃុំត្បូងក្រពើ ស្រុកសន្ទុក**

- ផ្នែកហេដ្ឋារចនាសម្ព័ន្ធ៖ ផ្លូវគមនាគមន៍ក្នុងឃុំសរុបមាន១៣ខ្សែ ប្រវែង ២៧,៧៨២ ម៉ែត្រ ក្នុងនោះផ្លូវប្រភេទបេតុងមាន ៤ខ្សែ ប្រវែង ២,០១២ម៉ែត្រ ដោយប្រើប្រាស់មូលនិធិឃុំ និងសប្បុរសជន មានផ្លូវក្រាលកៅស៊ូមានប្រវែង ៨,២០០ម៉ែត្រ ផ្លូវក្រាលគ្រួសក្រហម ២ខ្សែ ប្រវែង ១០,១២៦ម៉ែត្រ ប្រឡាយស្រោចស្រពមាន ៥ខ្សែ ប្រវែង ៤,៩១២ម៉ែត្រ។
- ឃុំបានរៀបចំបើកថ្នាក់មត្តេយ្យសហគមន៍ចំនួន ៧ថ្នាក់ និងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត ១កន្លែង មានសិស្សមត្តេយ្យសរុប ៧ ថ្នាក់។ ក្រសួងអប់រំសាងសង់មត្តេយ្យសហគមន៍ចំនួន ២ បន្ទប់, រដ្ឋបាលឃុំ និងសប្បុរសជនសាងសង់ ២ថ្នាក់ស្មើនឹង ២បន្ទប់, អង្គការដៃគូកំពុងសាងសង់មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមត្តេយ្យសហគមន៍ដោយមានចាក់សាប និងធ្វើរបងព័ទ្ធជុំវិញ។ ចលនាប្រជាពលរដ្ឋដាក់អំពូលភ្លើងសូឡាបំភ្លឺតាមផ្លូវក្នុងភូមិបាន ៣៥០អំពូល និងបានរៀបចំឱ្យមានប្រព័ន្ធទុយោទឹកស្អាតគ្រប់ភូមិ។
- ប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០២១ សរុបចំនួន ៣,៦៩៦ នាក់ ស្រី ១,៩៨៦ នាក់ ក្នុងនោះប្រជាពលរដ្ឋបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតថ្មីចំនួន ១៣៩ នាក់ ស្រី៧២ នាក់ អ្នកដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះបោះឆ្នោតចំនួន ៤០ នាក់ ស្រី១៩ នាក់។
- បានដាំកូនឈើក្នុងព្រៃសហគមន៍ និងនៅតាមសាលារៀន វត្តអារាម ផ្លូវសាធារណៈ។
- បានរៀបចំឱ្យមានប្រជាការពារប្រចាំការនៅតាមគោលដៅជារៀងរាល់ពេលយប់ ដោយបានសហការជាមួយកម្លាំងប៉ុស្តិ៍រដ្ឋបាលឃុំជាប្រចាំ។
- បានបង្កើតគណៈកម្មាធិការសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ ដើម្បីដោះស្រាយទំនាស់ជូនប្រជាពលរដ្ឋ។

- បានផ្សព្វផ្សាយ ស្តីពីការអនុវត្តវិធានការរបស់ក្រសួងសុខាភិបាល ស្តីពីការការពារជំងឺកូវីដ-១៩ និងបានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រចំនួន ៤១១គ្រួសារ។
- បានឧបត្ថម្ភជូនប្រជាពលរដ្ឋក្រីក្រ ចាស់ជរា ស្ត្រីមេម៉ាយ ក្មេងកំព្រា និងកុមារនៅទូទាំងឃុំ ដោយបានប្រើប្រាស់កញ្ចប់ថវិកាឃុំ សប្បុរសជន និងថវិកាផ្ទាល់ខ្លួនរបស់ក្រុមប្រឹក្សាឃុំ។

## III. ទិសដៅការងារបន្ត

### ❖ ក្រុមប្រឹក្សាខេត្ត

រដ្ឋបាលខេត្ត បានដាក់ចេញនូវទិសដៅការងារចាំបាច់មួយចំនួនដូច ខាងក្រោម៖

- បន្តពង្រឹងការផ្តល់សេវាសាធារណៈតាមរយៈយន្តការច្រកចេញចូលតែមួយ និងបន្តរៀបចំសាងសង់ អគារការិយាល័យច្រកចេញចូលតែមួយនៅតាមបណ្តាស្រុក ដែលមិនទាន់មាន។
- ជួយគាំទ្រ និងបង្កើនសមត្ថភាពដល់រដ្ឋបាលក្រុង ស្រុក លើការងារគ្រប់គ្រងធនធានមនុស្ស។
- ណែនាំ និងពិនិត្យសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ សោភណភាព គុណភាពសំណង់។
- បន្តជំរុញការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក សំដៅកាត់បន្ថយគ្រោះថ្នាក់ចរាចរ ឱ្យស្ថិតនៅកម្រិតទាប។
- បន្តរៀបចំវេទិកាសាធារណៈដើម្បីប្រមូលនូវសំណើ សំណូមពរ និងកង្វល់របស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។
- បន្តជំរុញការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋទូទាំងខេត្ត។
- ចាត់តាំងឱ្យមានក្រុមល្បាតដោយប្រើប្រាស់កម្លាំងសរុប មធ្យោបាយសរុប និងវិធានការសរុប ដើម្បីការពារ និងបង្ក្រាបបទល្មើសនានា ដែលកើតក្នុង តំបន់ព្រៃលិចទឹកបឹងទន្លេសាប។
- បន្តចូលរួមសកម្មភាពនានាក្នុងការប្រយុទ្ធនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ពិសេសបន្តអប់រំ និងណែនាំដល់ប្រជាពលរដ្ឋឱ្យអនុវត្តវិធានការ ៣កុំ និង ៣ការពារ។
- បន្តខិតខំអនុវត្តការតភ្ជាប់បណ្តាញអគ្គិសនីឱ្យបានគ្រប់ភូមិ ឃុំ ស្រុកទាំងអស់ក្នុងខេត្ត។

### ❖ ឃុំត្បូងក្រពើ ស្រុកសន្ទុក

- បន្តការយកចិត្តទុកដាក់បម្រើសេវារដ្ឋបាលជូនប្រជាពលរដ្ឋអោយលឿន រហ័ស និងមិនរើសអើង ប្រកបដោយការទទួលខុសត្រូវខ្ពស់
- បន្តការខិតខំពង្រឹងការអនុវត្តគោលនយោបាយ ភូមិឃុំមានសុវត្ថិភាព និងពង្រឹងការអនុវត្តតួនាទី ភារៈកិច្ច ដើម្បីធានាភាពសុខសាន្តរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន
- ពិនិត្យ និងប្រើប្រាស់មូលនិធិឃុំឱ្យស្របតាមសំណូមពររបស់ប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាល ដើម្បីបង្កើនភាពរីកចម្រើននៅក្នុងមូលដ្ឋាន

- បន្តការផ្សព្វផ្សាយពីវិធានការការពារការទប់ស្កាត់ ជំងឺឆ្លងនានា ពិសេសជំងឺកូវីដ-១៩ ប្រភេទថ្មី និងអនុវត្តវិធានការរបស់ក្រសួងសុខាភិបាលជាប្រចាំ
- ខិតខំគៀងគរអង្គការដៃគូ អ្នកវិនិយោគ និងសប្បុរសជនជិតឆ្ងាយ ដើម្បីចូលរួមអភិវឌ្ឍន៍ភូមិឃុំឱ្យមានភាពរីកចម្រើន។

## IV. សម្គាល់

- ក្រុមប្រឹក្សាឃុំត្បូងក្រពើ បានខិតខំយកចិត្តទុកដាក់ក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ ដោយមានវត្តមាននៅសាលាឃុំជានិច្ច ដើម្បីរង់ចាំបម្រើប្រជាពលរដ្ឋ ប្រកបដោយប្រសិទ្ធភាព មិនឱ្យមានការយឺតយ៉ាវ និងរាំងស្ទះឡើយ។ ក្នុងនោះ បានរៀបចំវេទិកាក្នុងការចុះជួបប្រជាពលរដ្ឋជារៀងរាល់ខែ ដើម្បីទទួលយកសំណូមពរ និងសង្កេតមើលបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋដោយផ្ទាល់ ព្រមទាំងដោះស្រាយផងដែរ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមករា ឆ្នាំ២០២២